ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ :០៣៣៧ សរ.ក/៧

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែតុលា ឆ្នាំ២០០៨

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ជំរាបមក**

**លោក ហួន ច័ន្ទធុន ចាងហ្វាងការផ្សាយសារព័ត៌មានសម្លេងអ្នកការពារ**

**កម្មវត្ថុ** : ករណីពាក់ព័ន្ធ នឹងសំណើសុំជួយអន្តរាគមន៍ ឱ្យសារព័តិមាន"សម្លេងអ្នកការពារ" បានចុះជួបសំភាសន៍ជាមួយមន្ត្រីថ្នាក់ស្រុក ខណ្ឌ ថ្នាក់ខេត្ត ក្រុង មួយចំនួន ដើម្បីយកព័តិមាន សន្តិសុខ និង ការអភិវឌ្ឍ សំរាប់ចុះផ្សាយ ។

**យោង** : លិខិតលេខ ០២៩/០៨ សកព ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ២០០៨ របស់សារព័តិមានសម្លេងអ្នកការពារ ។

តបតាមកម្មវត្ថុ និង យោងខាងលើ ខ្ញុំសូមជំរាបមក លោកចាងហ្វាងការផ្សាយសារព័តិមានសម្លេងអ្នកការពារ ថា អនុវត្តតាមច្បាប់ស្តីពីរបបសារព័តិមាន ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៨៩៥/០៧ ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ១៩៩៥ លោកមានសេរីភាពគ្រប់គ្រាន់ក្នុងការយកព័តិនៅគ្រប់ទិសទីក្នុងព្រះរាជាណាចក្រកម្ពុជាលើកលែងតែក្នុងករណីមួយចំនួន ដែលត្រូវបានហាមឃាត់ដោយច្បាប់នេះ ។

ពាក់ព័ន្ធនឹងករណីនេះ លោកត្រូវដាក់ពាក្យសុំសំភាសន៍ជាលាយល័ក្ខណ៍អក្សរទៅអង្គភាព ដែលលោកចង់យកព័តិមាន ស្របតាមនីតិវិធីដែលមានចែងក្នុងច្បាប់ស្តីពីរបបសារព័តិមាន ឬ សំរបសំរួលផ្ទាល់ជាមួយថ្នាក់ដឹកនាំនៃសាមីអង្គភាពនោះដើម្បីយកព័តិមាន។

អាស្រ័យហេតុនេះ សូមលោកចាងហ្វាងការផ្សាយ ជ្រាបជាព័តិមានផង។
សូមលោក ទទួលនូវការរាប់អាន ដ៏ស្មោះអំពីខ្ញុំ។

ស ខេង

**ចម្លងជូន**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងព័តិមាន
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
  *(ជូនជ្រាបជាព័តិមាន)*
- គ្រប់សាលាខេត្ត ក្រុង
  *(ដើម្បីជាព័តិមាន)*
- ឯកសារ

Kret Edit 061008